I-ផ្នែកការគណៈរដ្ឋមន្ត្រី

១-អនុក្រឹត្យ

រាជធានីភ្នំពេញ ថ្ងៃទី ០៧ ខែ វិច្ឆិកា ឆ្នាំ ១៩៩៤

អនុក្រឹត្យលេខ ៧១ អ.ន.ក្រ

ស្តីពីការបង្កើតក្រុមប្រឹក្សាស្តារ

អភិវឌ្ឍន៍វិស័យកសិកម្ម និងជនបទ

=========

រាជរដ្ឋាភិបាល

-បានឃើញរដ្ឋធម្មនុញ្ញ នៃ ព្រះរាជាណាចក្រកម្ពុជា

-បានឃើញព្រះរាជក្រឹត្យរបស់ព្រះករុណាព្រះបាទសម្តេចព្រះ នរោត្តម សីហនុ វរ្ម័ន ព្រះមហាក្សត្រនៃព្រះរាជាណាចក្រកម្ពុជា ចុះថ្ងៃទី ០១ ខែ វិច្ឆិកា ឆ្នាំ ១៩៩៣ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលកម្ពុជា

-បានឃើញច្បាប់ស្តីពីការរៀបចំ និង ការប្រព្រឹត្តិទៅនៃគណៈរដ្ឋមន្ត្រី ចុះថ្ងៃទី ១៩ ខែ កក្កដា ឆ្នាំ ១៩៩៤ ដែលប្រកាសអោយប្រើដោយព្រះរាជក្រម ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៤

-យោងតាមសំណូមពរការងារចាំបាច់

សំរេច

មាត្រា ១ : បង្កើតក្រុមប្រឹក្សាស្តារអភិវឌ្ឍន៍វិស័យកសិកម្ម និងជនបទ ដែលមានសមាសភាព ដូចតទៅ :

១-សម្តេច ហ៊ុន សែន នាយករដ្ឋមន្ត្រីទី២ ប្រធាន

២-ឯកឧត្តម តាវ សេងហួរ រដ្ឋមន្ត្រីក្រសួងកសិកម្ម រុក្ខាប្រមាញ់ និង នេសាទ អនុប្រធាន

៣-ឯកឧត្តម គាត ឈន់ ទេសរដ្ឋមន្ត្រីទទួលបន្ទុកកិច្ចការនិតិសម្បទា និងអភិវឌ្ឍន៍ រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ សមាជិក

៤-ឯកឧត្តម ថៅ ចេងឈាត អគ្គទេសាភិបាលនៃធនាគារជាតិកម្ពុជា សមាជិក

៥-ឯកឧត្តម ចម ប្រសិទ្ធ រដ្ឋមន្ត្រីក្រសួងពាណិជ្ជកម្ម សមាជិក

៦-ឯកឧត្តម ជា ចាន់តូ រដ្ឋមន្ត្រីក្រសួងផែនការ សមាជិក

៧-ឯកឧត្តម ហុង ស៊ុនហួត រដ្ឋមន្ត្រីក្រសួងអភិវឌ្ឍន៍ជនបទ សមាជិក

៨-ឯកឧត្តម នួន គានុន រដ្ឋលេខាធិការទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី សមាជិក

៩-ឯកឧត្តម ត្រាំ អ៊ីវតឹក រដ្ឋលេខាធិការក្រសួងសាធារណៈការ និងដឹកជញ្ជូន សមាជិក

១០-លោក ជុំ ប៊ុកវ៉ុង ទីប្រឹក្សាសម្តេចនាយករដ្ឋមន្ត្រីទី២ សមាជិក

១១-លោក លឹម គានហោ ប្រធាននាយកដ្ឋានធារាសាស្ត្រ ឧតុនិយម និង ជលសាស្ត្រ សមាជិក

១២-លោក សារ៉ាក់ ខាន់ មន្ត្រីទីស្តីការគណៈរដ្ឋមន្ត្រី អគ្គលេខាធិការ

មាត្រា ២ : ក្រុមប្រឹក្សាស្តារ អភិវឌ្ឍន៍វិស័យកសិកម្ម និងជនបទ មានតួនាទីជាគណៈបញ្ជាការឯកភាពមួយ ដោយសហការគ្នាយ៉ាងជិតស្និទ្ធជាមួយបណ្តាក្រសួងស្ថាប័នមានសមត្ថកិច្ចពាក់ព័ន្ធ ជាពិសេស ជាមួយក្រុមប្រឹក្សាអភិវឌ្ឍន៍កម្ពុជា ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ ក្រសួងអភិវឌ្ឍន៍ជនបទ ដើម្បីអនុវត្តឲ្យស៊ីសង្វាក់ ប្រទាក់ក្រឡាគ្នា និងមានប្រសិទ្ធភាព ព្រមទាំងមាន

សិទ្ធិសំរេចអំពីមធ្យោបាយ សំភារៈ ទុន និងការងារផ្សេង ៗ ទៀត ដែលជួយឲ្យសំរេចរាល់ភារកិច្ចដែលមានចែងក្នុងមាត្រា៣ ។

មាត្រា ៣ : ក្រុមប្រឹក្សាស្តារ អភិវឌ្ឍន៍វិស័យកសិកម្ម និងជនបទ មានភារកិច្ចដូចខាងក្រោម :

- ទទួលបន្ទុកចាត់ចែងអនុវត្តនូវកម្មវិធីនយោបាយរបស់រាជរដ្ឋាភិបាល និងកម្មវិធីជាតិនិតិសម្បទា និងអភិវឌ្ឍន៍កម្ពុជា លើកិច្ចការស្តារ និង អភិវឌ្ឍន៍វិស័យកសិកម្ម និងជនបទ សំដៅប្រែក្លាយវិស័យកសិកម្មដែលមានទំលាប់ធ្វើដើម្បីផ្គត់ផ្គង់ខ្លួនឯង ឲ្យទៅជាការផលិតដើម្បីនាំចេញ ព្រមទាំងបន្ថយជាជំហាន ៗ នូវគម្លាតឆ្ងាយរវាងជនបទ និង ទីក្រុង ។
- កំណត់កត្តាគន្លឹះទាំងឡាយដែលបំរើឲ្យការស្តារ និង អភិវឌ្ឍន៍វិស័យកសិកម្ម និង ជនបទ ។
- កំណត់អាទិភាពនៃតម្រូវការក្នុងការស្តារ និង អភិវឌ្ឍន៍វិស័យកសិកម្ម និង ជនបទ ទៅតាមកម្មវិធី និងតាមសភាពការណ៍ជាក់ស្តែង ។
- ចលនា និងសំរបសំរួលរវាងគ្រប់សមាសភាពសេដ្ឋកិច្ច ជាពិសេសក្រុមហ៊ុនឯកជនជាមួយក្រសួង ស្ថាប័ន ខេត្ត ក្រុង ដើម្បីបង្កនូវភាពងាយស្រួល និងភាពសហការគ្នាល្អក្នុងការស្តារ និងអភិវឌ្ឍន៍វិស័យកសិកម្ម និងជនបទ។
- ពិនិត្យ និងសំរេចលើរាល់សេចក្តីស្នើសុំស្តារ និងអភិវឌ្ឍន៍វិស័យកសិកម្ម និង ជនបទ ព្រមទាំងផ្តល់យោបល់ណែនាំដល់ក្រសួង ស្ថាប័ន និង ខេត្ត ក្រុង ។ រាយការណ៍ និងសុំយោបល់រាជរដ្ឋាភិបាលលើបញ្ហាសំខាន់ ៗ ដែលស្ថិតក្នុង សមត្ថកិច្ចរបស់រាជរដ្ឋាភិបាល ។

មាត្រា ៤ : ក្រុមប្រឹក្សាស្តារ អភិវឌ្ឍន៍វិស័យកសិកម្ម និង ជនបទ មានភារកិច្ចបង្កើតលេខាធិការដ្ឋានមួយ ដើម្បីជួយការងារ ។

មាត្រា ៥ : សមាជិកក្រុមប្រឹក្សាស្តារ អភិវឌ្ឍន៍វិស័យកសិកម្ម និងជនបទ ត្រូវចូលរួមប្រជុំតាមការអញ្ជើញរបស់ប្រធាន ។

មាត្រា ៦ : ក្រុមប្រឹក្សាស្តារ អភិវឌ្ឍន៍វិស័យកសិកម្ម និងជនបទ មានសិទ្ធិប្រើប្រាស់ត្រារបស់គណៈរដ្ឋមន្ត្រី ។

មាត្រា ៧ : ក្រុមប្រឹក្សាស្តារ អភិវឌ្ឍន៍វិស័យកសិកម្ម និងជនបទ ត្រូវរៀបចំបទបញ្ជាផ្ទៃក្នុងរបស់ខ្លួន សំរាប់ដំណើរការជាក់ស្តែង ។

មាត្រា ៨ : សហរដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងកសិកម្ម រុក្ខា ប្រមាញ់ និង នេសាទ រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ អគ្គទេសាភិបាលនៃធនាគារជាតិកម្ពុជា រដ្ឋមន្ត្រីក្រសួងពាណិជ្ជកម្ម រដ្ឋមន្ត្រីក្រសួងផែនការ រដ្ឋមន្ត្រីក្រសួងអភិវឌ្ឍន៍ជនបទ និង សម្តេច ឯកឧត្តម អស់លោក ដែលមានឈ្មោះក្នុងមាត្រា ១ ព្រមទាំងបណ្តាក្រសួង-ស្ថាប័ន និង ខេត្ត ក្រុង ដែលមានការពាក់ព័ន្ធ ត្រូវទទួលអនុវត្តតាមអនុក្រឹត្យនេះ ចាប់ពីថ្ងៃឡាយព្រះហស្តលេខា និង ចុះហត្ថលេខាតទៅ ។

នាយករដ្ឋមន្ត្រីទី១	នាយករដ្ឋមន្ត្រីទី២
ព្រះហស្តលេខា និងត្រា	ហត្ថលេខា និងត្រា
នរោត្តម រណឫទ្ធិ	**ហ៊ុន សែន**

* * *

រាជធានីភ្នំពេញ, ថ្ងៃទី ០៣ ខែ វិច្ឆិកា ឆ្នាំ ១៩៩៨

អនុក្រឹត្យលេខ ១២៦ អ.ន.ក្រ

ស្តីពីការតែងតាំងមន្ត្រីរាជការ

*****

-បានឃើញរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា